# ជំនឿច្រឡំច្របល់

មុនប្រវត្តិសាស្ត្រគឺមុនព្រះពុទ្ធសាសនានិងព្រហ្មញ្ញសាសនាចូលមកស្រុកខ្មែរ ប្រជាជនខ្មែរបានមានជំនឿរបស់ខ្លួនរួចស្រេចហើយដូចជាជឿព្រលឹង អារក្សអ្នកតា ព្រៃព្រឹក្សានិងដុំថ្មជាដើម ។ ចាប់ពីសតវត្សទី១ដល់សតវត្សទី៦ រាជវង្សានុវង្សនិងនាម៉ឺនសព្វមុខមន្ត្រីខ្មែរបានមានជំនឿលើព្រហ្មញ្ញសាសនា ចំណែកប្រជានុរាស្ត្រនាំគ្នាជឿលើព្រះពុទ្ធសាសនាមហាយាន ។ ចាប់ពីសតវត្សទី៧ដល់សតវត្សទី១១ ទាំងស្តេចនាម៉ឺននិងប្រជារាស្ត្រគ្រប់ស្រទាប់បាននាំគ្នាគោរពជឿលើព្រហ្មញ្ញសាសនា ។ គឺក្នុងរយៈពេលនោះហើយដែលព្រះបាទសុរិយាវរ្ម័នទី២បានកសាងប្រាសាទអង្គរវត្តដ៏ល្អស្រស់ប្រិមប្រិយដើម្បីឧទ្ទិសថ្វាយដល់សាសនារបស់ព្រះអង្គ ។ ចាប់ពីសតវត្សទី១២ដល់សតវត្សទី១៣ រាស្ត្រខ្មែរទាំងនគរបានបំបែរជំនឿរបស់ខ្លួនមកគោរពជឿលើព្រះពុទ្ធសាសនាមហាយានវិញ ។ ប្រាសាទបាយ័នប្រកបដោយកំពូលប្រាង្គមុខ៤ទាំងតូចទាំងធំចំនួន៥៤កំពូលកសាងឡើងដោយព្រះបាទជ័យវរ្ម័នទី៧ដើម្បីឧទ្ទិសដល់ព្រះអវលោកេស្វរៈដែលជាព្រះពោធិសត្វសំខាន់ជាងគេក្នុងព្រះពុទ្ធសាសនាមហាយាន បានបញ្ជាក់យ៉ាងច្បាស់លាស់នូវជំនឿដ៏មុតមាំរបស់ខ្មែរនាសម័យនោះ ។ ចាប់ពីសតវត្សទី១៤រហូតមកដល់សព្វថ្ងៃ ប្រជាជនខ្មែរទាំងនគរបាននាំគ្នាគោរពជឿលើព្រះពុទ្ធសាសនាហីនយានដែលនាំមកពីលង្កាទ្វីបវិញ ។ ប្រវត្តិសាស្ត្រខ្មែរយើងខ្លះបានគូសបញ្ជាក់យ៉ាងល្អិតថែមទៀតថា ពិតមែនតែក្នុងរយៈពេលខ្លះខ្មែរបានគោរពជឿលើព្រះពុទ្ធសាសនាមហាយានក៏ដោយ តែព្រហ្មញ្ញសាសនានៅតែមានការសន្តោសប្រោសប្រណីពីស្តេចផែនដីឱ្យរស់រានមានជីវិតដើម្បីបម្រើជំនឿខ្មែរផងដែរ ។ ក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី២ (១២០១-១២៤០)សេរីភាពខាងជំនឿសាសនាមានភាពទូលំទូលាយសម្បើមណាស់ ដោយព្រះអង្គបានទ្រង់ប្រោសប្រណីដល់សាសនាទាំងពីរឱ្យធ្វើពិធីការសាសនាចូលគ្នាជាផ្លូងមួយក្នុងពិធីបុណ្យនានា ព្រមទាំងអនុញ្ញាតដល់ប្រជាជនឱ្យមានជំនឿសាសនាដោយសេរី ។ អំពើអស់ទាំងនេះត្រូវបានទទួលការនិយមរាប់អានយ៉ាងខ្លាំងពីសង្គមខ្មែរ ព្រមទាំងបានចាក់ឫសយ៉ាងជ្រៅទៅក្នុងក្រអៅបេះដូងខ្មែរគ្រប់រូប ហើយបន្ទាប់មកបានក្លាយទៅជាទំនៀមទំលាប់ប្រពៃណីរបស់ខ្មែរថែមទៀតផង ។ ពិតមែនតែខ្មែរទាំងនគរបានប្រកាសខ្លួនថាជាពុទ្ធសាសនិកជនស្អាតបរិសុទ្ធហើយបានទាំងចារដាក់ក្នុងរដ្ឋធម្មនុញ្ញថា ព្រះពុទ្ធសាសនាជាសាសនារបស់ខ្មែរ ក៏សព្វថ្ងៃនេះគេនៅតែសង្កេតឃើញច្បាស់ថាឥទ្ធិពលផ្នែកទ្រឹស្តីចិត្តគំនិតនៃព្រហ្មញ្ញសាសនាចំនួនមួយសំពាយធំនៅតែមានភាពល្អក់ល្អិនស្អិតល្អួតក្នុងសង្គមខ្មែរនៅឡើយ ។ ជំនឿច្របូកច្របល់នេះជាបុព្វហេតុធ្វើឱ្យបរិស័ទភាគច្រើនដែលខ្វះការសិក្សាស្រាវជ្រាវនិងវិចារណញ្ញាណមានការយល់ច្រឡំថា ព្រះពុទ្ធសាសនាជាព្រហ្មញ្ញសាសនាៗជាព្រះពុទ្ធសាសនា ដោយគេគិតស្មានថាសាសនាទាំងពីរនេះបានចម្លងគ្នាទៅវិញទៅមកដូចគ្នាបេះបិទគ្មានអ្វីចម្លែកប្លែកពីគ្នាទេ ។

ពិតមែនតែព្រះពុទ្ធសាសនាមានកំណើតក្រោយព្រហ្មញ្ញសាសនាជាងមួយពាន់ឆ្នាំក៏ដោយ ក៏សាសនាថ្មីនេះសម្បូរហូរហៀរទៅដោយឧត្តមគតិដែលជាពាក្យអប់រំទូន្មានប្រៀនប្រដៅដ៏ល្អសមរម្យសមហេតុសមផលគួរជឿគួរគោរពគួរអនុវត្តឱ្យបានសម្រេចនូវប្រយោជន៍ល្អជាងនិងល្អលើសព្រហ្មញ្ញសាសនាឆ្ងាយពេកណាស់ ។ នេះហើយជាបុព្វហេតុដ៏ចំបងដែលធ្វើឱ្យព្រះបាទសិទ្ធត្ថជាស្ដេចបរិបូរណ៍ដោយគំនរមហាសុខ លះបង់គ្រប់បែបយ៉ាងដើម្បីប្ដូរយកព្រះធម៌ដែលហៅថាព្រះពុទ្ធសាសនានោះ ។

សួរថាតើ ព្រះពុទ្ធសាសនានិងព្រហ្មញ្ញសាសនាមានអត្ថន័យ អត្ថរូបព្រមទាំងអត្ថរសខុសគ្នាយ៉ាងណាខ្លះ? នេះជាភារកិច្ចរបស់ខ្មែរយើងជាពុទ្ធបរិស័ទគ្រប់រូបដែលត្រូវតែមានចិត្តមានះខិតខំសិក្សារៀនសូត្រសង្កេតពិនិត្យពិចារណារកការពិតនៃសាសនានីមួយៗរួចហើយត្រូវនាំគ្នាផ្សព្វផ្សាយនូវការពិតអស់ទាំងនោះឱ្យបានទូលំទូលាយទៅតាមសមត្ថភាពរៀងៗខ្លួន ដើម្បីបង្ហាញថាយើងជាពុទ្ធបុត្រកូនព្រះឈ្នះមារមានការចេះដឹងគ្រប់គ្រាន់ ចេះឆ្លើះបំផុសបង្ហាត់បង្ហាញពន្យល់ណែនាំដល់បរិស័ទឱ្យឃើញជាក់ច្បាស់នូវធាតុពិតដ៏ឧត្តមថ្លៃថ្លានៃសាសនារបស់យើងដែលធ្លាប់តែកប់បាត់ស្ងាត់សូន្យជាយូរមកហើយនោះ ៕